**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២៨. អនក្រ. បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា ១០ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក**

**ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី**

**របៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- អនុក្រឹត្យលេខ ៥៤ អនុក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីរបៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្មចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០០២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រាមួយ.-**

មាត្រា ១០ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពី របៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ត្រូវបានធ្វើការកែសម្រួលដូចតទៅៈ

**មាត្រា ១០.-ថ្មី**

ក/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- មានអាយុយ៉ាងតិច ២៥ឆ្នាំ

៣- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៤- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និង សិទ្ធិខាងនយោបាយ

ខ/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម និង ជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម និង បានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋត្រឹមត្រូវនៅឆ្នាំអាជីវកម្ម កន្លងមក

៣- មានអាយុយ៉ាងតិច ២៥ឆ្នាំ

៤- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៥- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និង សិទ្ធិខាងនយោបាយ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ